**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាលាភូមិន្ទអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត **សាលាភូមិន្ទអាជ្ញាសាលា** ស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា ២.-**

សាលាភូមិន្ទអាជ្ញាសាលា មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ទទួលបន្ទុកការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង និងបណ្តុះបណ្តាលបន្ត សម្រាប់អាជ្ញាសាលា
- លើកយុទ្ធសាស្ត្រការងារ និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈអាជ្ញាសាលា
- រៀបចំតាក់តែងឯកសារគរុកោសល្យសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈអាជ្ញាសាលា
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ សម្រាប់បណ្តុះបណ្តាល អាជ្ញាសាលា
- តាមដានត្រួតពិនិត្យការសិក្សា និង ការគោរពវិន័យរបស់សិស្សអាជ្ញាសាលា
- ត្រួតពិនិត្យការធ្វើកម្មសិក្សារបស់សិស្សអាជ្ញាសាលា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាពសីលធម៌ និងគម្រោងការអភិវឌ្ឍន៍របស់សាលា ជូនប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការមុននឹងបញ្ជូនទៅក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ត្រួតពិនិត្យ និងចាត់ចែងលើការងារដឹកនាំរបស់ផ្នែកចំណុះ ។

ការបណ្តុះបណ្តាលអាជ្ញាសាលា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយសហការជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៣.-**

សាលាភូមិន្ទអាជ្ញាសាលា មានផ្នែកចំណុះពីរគឺ ៖

- ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់អាជ្ញាសាលា
- ផ្នែកបណ្តុះបណ្តាលបន្តសម្រាប់អាជ្ញាសាលា ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអាចមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។

ប្រធានផ្នែកនីមួយៗ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាភូមិន្ទអាជ្ញាសាលា ត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

**មាត្រា ៤.-**

សាលាភូមិន្ទអាជ្ញាសាលា ដឹកនាំការងារបច្ចេកទេស ដោយនាយកមួយរូប ។

នាយកសាលាភូមិន្ទអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

នាយកសាលាភូមិន្ទអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ឬ ឥស្សរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក នីតិសាស្ត្រ ឬផ្នែកគ្រប់គ្រង ឡើងទៅ ។

នាយកសាលាភូមិន្ទអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គឺជាសមាជិកអញ្ជើញរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៤
## ការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលា និង ការបណ្តុះបណ្តាល

**មាត្រា ៥.-**

ការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវទទួលបន្ទុករៀបចំការប្រឡងប្រជែងជ្រើសរើស សិស្សអាជ្ញាសាលា ដោយមានការចូលរួមសហការពីក្រសួងយុត្តិធម៌ ។

**មាត្រា ៦.-**

បេក្ខជនដែលប្រឡងប្រជែងចូលសាលាភូមិន្ទអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការ ត្រូវមានអាយុមិនលើសពី ៤០ឆ្នាំ គិតមកត្រឹមថ្ងៃប្រឡង
- ត្រូវមានសញ្ញាប័ត្របរិញ្ញាបត្រនីតិសាស្ត្រ ឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់ជាប់ទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ ។

**មាត្រា ៧.-**

បេក្ខជនដែលបានប្រឡងប្រជែងជាប់ជាស្ថាពរនៅសាលាភូមិន្ទអាជ្ញាសាលានៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងជាសិស្សអាជ្ញាសាលា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ ក្នុងរយៈពេលនៃការបណ្តុះបណ្តាល សិស្សអាជ្ញាសាលា ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមការកំណត់របស់រដ្ឋ ។

**មាត្រា ៨.-**

សិស្សអាជ្ញាសាលា ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់អាជ្ញាសាលា ឱ្យបានពេញលេញតាមកម្មវិធីសិក្សា ដែលត្រូវកំណត់ដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

សិស្សអាជ្ញាសាលា ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងសម្រាប់អាជ្ញាសាលា ដោយជោគជ័យ ត្រូវទទួលបានសញ្ញាប័ត្រវិជ្ជាជីវៈអាជ្ញាសាលា ដែលចេញដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៥
## ធនធានហិរញ្ញវត្ថុ

**មាត្រា ៩.-**

សាលាភូមិន្ទអាជ្ញាសាលា មានថវិកា ដែលផ្គត់ផ្គង់ដោយរដ្ឋ សម្រាប់អនុវត្តការងាររបស់ខ្លួន ។

ថវិការបស់សាលាភូមិន្ទអាជ្ញាសាលា គឺស្ថិតនៅក្នុងកញ្ចប់ថវិការបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៨*

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១១*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*